**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

មូលនិធិជាតិ ជំនួយ សង្គម
NATIONAL SOCIAL ASSISTANCE FUND
មូលនិធិជាតិជំនួយសង្គម

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំធ្វើបច្ចុប្បន្នភាពបណ្ណ ប.ស.ស. ជូនអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន

ដោយយោងតាមលិខិតលេខ១៨០៦/២៥ ប.ស.ស. ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៥ របស់បេឡាជាតិសន្តិសុខសង្គមនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.) សូមគោរពជម្រាបជូនដំណឹងដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនទាំងអស់ឱ្យបានជ្រាបថា ដើម្បីធានាបាននូវប្រសិទ្ធភាព ស្ថិរភាព និងនិរន្តរភាពនៃការថែទាំផ្នែកសុខភាព ព្រមទាំងជួយសម្រួលជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនក្នុងការទៅប្រើប្រាស់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រនៅមូលដ្ឋានសុខាភិបាលដែលជាដៃគូ (ប.ស.ស) ឱ្យកាន់តែមានភាពងាយស្រួល ដោយពុំចាំបាច់ភ្ជាប់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទៅជាមួយនៅពេលប្រើប្រាស់បណ្ណសមាជិក (ប.ស.ស.) ទៀតនោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន អាចអញ្ជើញទៅធ្វើបច្ចុប្បន្នភាពបណ្ណសមាជិក(ប.ស.ស.) (បន្ថែមរូបថត និងស្នាមក្រយៅដៃ) នៅសាខាបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) រាជធានី ខេត្ត ដែលនៅជិតបំផុត។

ទន្ទឹមនឹងនេះ ចំពោះអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ដែលមានបណ្ណប.ស.ស. មានបញ្ហាដូចជា ខូច ខុសឈ្មោះ ឬបាត់ សូមអញ្ជើញទៅខាសាមូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.) រាជធានី ខេត្ត ដើម្បីធ្វើលិខិតបញ្ជាក់ស្នើសុំបណ្ណប.ស.ស. ថ្មី (ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានសុពលភាព និងរូបថត ៤x៦ ១សន្លឹក ឯកសណ្ឋានស៊ីវិល)។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងសូមអញ្ជើញទៅធ្វើបច្ចុប្បន្នភាពបណ្ណសមាជិក (ប.ស.ស.) ឱ្យបានគ្រប់ៗគ្នា។

ថ្ងៃ[illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២៥

ម.ជ.ជ.

មូលនិធិជាតិជំនួយសង្គម, អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ០៩២ ២១៩ ៨៨៨ / ០៣១ ៥ ២១៩ ៨៨៨ / ទូរសារ : (៨៥៥) ០២៣ ៩៨៧ ៥១២
National Social Assistance Fund, #788, Monivong Blvd., Phnom Penh, Camnbodia. Fax/Phone: (855) 023 987 512 / 092 219 888 / 031 5 219 888